ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី៣ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧

រៀបចំដោយៈ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយៈ ថវិកាជាតិ

## ១. សេចក្តីផ្តើម៖

នៅព្រឹកថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៣ សម្រាប់ឆ្នាំ២០១៧ ក្រោមការដឹកនាំរបស់ **ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង-ស្ថាប័ន ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើការងារមេរោគអេដស៍ និងជំងឺអេដស៍។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីថវិកាជាតិ។

## ២. គោលបំណងនៃកិច្ចប្រជុំ៖

ដើម្បីបង្ហាញពីរបាយការណ៍វឌ្ឍនភាព សមិទ្ធផល និងទិសដៅបន្តក្នុងការឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ ព្រមទាំងពិភាក្សា សម្របសម្រួលការងារបច្ចេកទេសតាមរបៀបវារៈ ដូចខាងក្រោម៖

-មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំ

-របាយការណ៍ប្រចាំខែ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-បទបង្ហាញពីស្ថានភាពរបស់ក្រុមប្រឈមមុខខ្ពស់ទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅរាជធានីភ្នំពេញ

-បទបង្ហាញផ្សព្វផ្សាយពីរបាយការណ៍អង្កេតជាតិស្តីពីការចំណាយក្នុងការប្រយុទ្ធនឹងជំងឺអេដស៍

-បទបង្ហាញពីការរៀបចំថវិកាប្រចាំឆ្នាំ២០១៨ របស់សមាជិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-បញ្ហាផ្សេងៗ។

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណ ដល់សមាជិក-សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ដែលបានអញ្ជើញចូលរួមនាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុក។

**ប្រធានបទទី១៖ ឯកឧត្តមវេជ្ជបណ្ឌិត ងា ចៅ** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជម្រាប ជូនពីរបាយការណ៍សង្ខេបរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានធ្វើក្នុង ខែមេសា ឆ្នាំ២០១៧ ដូចខាង ក្រោម៖

- នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៧ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តព្រៃវែង។ ឯកឧត្តមអគ្គលេខាធិការបានកោតសរសើរចំពោះការប្រយុទ្ធនឹងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ ដែលបានរួមគ្នាពុះពារការលំបាក ដើម្បីថែរក្សាសុខភាព ប្រជាពលរដ្ឋ ជាពិសេសទប់ស្កាត់មិនឱ្យមានការឆ្លងថ្មី ទោះបីស្ថិតក្នុងសភាពប្រឈមនឹងបញ្ហាថវិកាមិន គ្រប់គ្រាន់យ៉ាងណាក្តី។ បន្ទាប់មក ឯកឧត្តមអគ្គលេខាធិការក៏បានចុះជួបជាមួយម្ចាស់សេវាកំសាន្តផងដែរ ដើម្បីលើកទឹកចិត្ត និងជំរុញការប្រើប្រាស់ស្រោមអនាម័យ១០០ % ។

- នៅថ្ងៃទី៥-៦ ខែមេសា ឆ្នាំ២០១៧ នៅសណ្ឋាគារសាន់វេ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ពីយុទ្ធសាស្ត្រទំនាក់ទំនងការការពារកុមារពីអំពើហឹង្សា និងការបំបែកកុមារពីគ្រួសារដោយមិនចាំបាច់ ដែលរៀបចំដោយអង្គការ UNICEF ។

- នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៧ នាខេត្តក្រចេះ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចូលរួមធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការបង្ការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងវិស័យទេសចរណ៍ដល់ប្រតិបត្តិករទេសចរណ៍ រួមមានម្ចាស់ ឬអ្នកគ្រប់គ្រងមូលដ្ឋានអាជីវកម្ម សេវាកម្មសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន មណ្ឌលកម្សាន្តទេសចរណ៍ មគ្គុទេសចរណ៍ និងនារីផ្សព្វផ្សាយស្រាបៀរ។

- បានបញ្ចប់របាយការណ៍វឌ្ឍនភាពនៃឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា ផ្ញើទៅអង្គការសហប្រជាជាតិ សម្រាប់ឆ្នាំ២០១៧ ( GARPR 2017 )។

- បានរៀបចំសេចក្តីព្រាងរបៀបវារៈ សម្រាប់កិច្ចប្រជុំពេញអង្គរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលគ្រោងប្រព្រឹត្តទៅក្នុងខែកក្កដា ឆ្នាំ២០១៧ ។

- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានទំនាក់ទំនងជាមួយអគ្គនាយកវិទ្យុជាតិ ដើម្បីសម្របសម្រួល និងពិភាក្សាពីនីតិវិធីធ្វើសិក្ខាសាលាស្តីពីការបញ្ជ្រាបកម្មវិធីឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមអ្នកសារព័ត៌មាន វិទ្យុ ទូរទស្សន៍ និងវិស័យឯកជន។ ជាលទ្ធផលក្រសួងព័ត៌មានបានបញ្ជូនបញ្ជីឈ្មោះជាអក្សរខ្មែរ និងអក្សរឡាតាំងមកនាយកដ្ឋានរួចរាល់ សម្រាប់រៀបចំសិក្ខាសាលាជាមួយអ្នកសារព័ត៌មាននៅខេត្តព្រះសីហនុ នាថ្ងៃទី២២-២៣ ខែឧសភា ឆ្នាំ២០១៧។

- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំសេចក្តីសម្រេចចិត្តស្តីពីការបង្កើតក្រុមការងារចម្រុះដើម្បីជានានិរន្តភាពនៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងការកំណត់អាទិភាព សម្របសម្រួល និងការគាំទ្រដល់ការរៀបចំគោលការណ៍ណែនាំសម្រាប់កម្មវិធីឆ្លើយតបមេរោគអេដស៍ ថ្នាក់ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។

- នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ អគ្គលេខាធិការដ្ឋានបានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារបច្ចេកទេសថ្នាក់ជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងចំណោមបុរសស្រឡាញ់បុរស និងស្រីស្រស់ ។

- អគ្គលេខាធិការដ្ឋានបានសម្របសម្រួលជាមួយខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តព្រះសីហនុ ខេត្តកំពង់ចាម និងរាជធានីភ្នំពេញ ដើម្បីត្រៀមរៀបចំសិក្ខាសាលាចំនួន២ នាខែឧសភាខាងមុខ។

**<u>ផែនការសកម្មភាព និងទិសដៅបន្ត៖</u>**

- បន្តរៀបចំតាមដានសេចក្តីសម្រេចចិត្តស្តីពីការបង្កើតក្រុមការងារចម្រុះជានានិរន្តភាព នៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ក្នុងការកំណត់អាទិភាពសម្របសម្រួល និងការគាំទ្រដល់ការរៀបចំគោលការណ៍ណែនាំសម្រាប់កម្មវិធីឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ថ្នាក់ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។

➢ បន្តរៀបចំសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ ស្តីពីការចំណាយលើការប្រយុទ្ធនឹងជំងឺអេដស៍លើកទី៥ សម្រាប់ឆ្នាំ២០១៤ និង២០១៥ ដល់អ្នកពាក់ព័ន្ធ ដែលគ្រោងធ្វើនៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុននាថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៧ ។

➢ ជូនដំណឹងដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង-ស្ថាប័ន និងខេត្តឱ្យលើកគម្រោងរៀបចំការប្រជុំប្រចាំឆមាស។

➢ បន្តសម្របសម្រួលជាមួយថ្នាក់ខេត្ត (សៀមរាប បន្ទាយមានជ័យ បាត់ដំបង ព្រះសីហនុ កំពង់ចាម និងរាជធានីភ្នំពេញ) សម្រាប់រៀបចំសិក្ខាសាលា ចំនួន២ ក្នុងខែឧសភា៖

- សិក្ខាសាលា ផ្លាស់ប្តូរបទពិសោធន៍ស្តីពីការគាំទ្របរិយាកាសអំណោយផល សម្រាប់ក្រុមប្រជាជនប្រឈមមុខខ្ពស់ ( ១៨ ឧសភា ឆ្នាំ២០១៧ នៅខេត្ត កំពត)
- សិក្ខាសាលាស្តីពីការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ តាមរយៈកម្មវិធីដៃគូសហគមន៍សម្រាប់ក្រុមប្រជាជនប្រឈមមុខខ្ពស់ (៣១ ឧសភា ឆ្នាំ២០១៧ នៅ រាជធានីភ្នំពេញ)។

ក្រោយពីបង្ហាញចប់ **ឯកឧត្តមប្រធានអង្គប្រជុំ** បានស្នើឱ្យបន្ថែមនូវសកម្មភាពដែលសមាជិកក្រុមការងារបានធ្វើកន្លងមក សម្រាប់ដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**តំណាងក្រសួងទេសចរណ៍៖ បានថ្លែងអំណរគុណចំពោះការចូលរួមសហការរបស់អាជ្ញាធរជាតិប្រយុទ្ធនឹង**ជំងឺអេដស៍ ក្នុងការធ្វើបទបង្ហាញនៅខេត្តក្រចេះពីបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ ដល់ម្ចាស់សេវា ម្ចាស់សណ្ឋាគារ ភោជនីយដ្ឋាន និងមគ្គុទេសចរណ៍។

**តំណាងក្រសួងអភិវឌ្ឍន៍ជនបទ** ៖ បានទទួលថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ផ្សព្វផ្សាយពីមេរោគអេដស៍ និងជំងឺអេដស៍ និងសំណូមពរអោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បើកវគ្គបណ្តុះបណ្តាលពីបច្ចុប្បន្នភាពនៃការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ដល់សមាជិក-សមាជិកាថ្មី ដែលទើបតែងតាំងមកពីក្រសួង-ស្ថាប័ន ដែលជាសមាជិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**តំណាងក្រសួងបរិស្ថាន** ៖ បានសហការជាមួយសម្ព័ន្ធយុវជនកម្ពុជាតាមរយៈការបោះតង់ ហើយបានបញ្ជ្រាបពីបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ដល់ពួកគាត់ដោយប្រើប្រាស់ថវិកាផ្ទាល់ខ្លួនរបស់យុវជន។

**ប្រធានបទទី២៖** បទបង្ហាញពីស្ថានភាពរបស់ក្រុមប្រឈមមុខខ្ពស់ទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅរាជធានីភ្នំពេញដោយ **លោកវេជ្ជបណ្ឌិត ឡុង ឡាទី** ប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ៖

ភ្នំពេញមានផ្ទៃដីសរុប ៦៧៨,៤៣គីឡូម៉ែត្រក្រឡា។ មានខណ្ឌរដ្ឋបាលចំនួន១២ សង្កាត់ចំនួន៩៦ និងភូមិ៩០៩។ ក្នុងឆ្នាំ២០១៦ មានប្រជាជនសរុប ចំនួន១,៦៨៨,០៤៤នាក់ ចំនួនគ្រួសារមាន២៩៣,២៣២ ដង់ស៊ីតេប្រជាជនជាមធ្យមមាន ២,១៣១នាក់/គីឡូម៉ែត្រការ៉េ និងទំហំគ្រួសារមានសមាជិកចំនួន៥នាក់។ មន្ទីរសុខាភិបាលរាជធានីភ្នំពេញមាន:

- ការិយាល័យជំនាញចំនួន ០៤

- ការិយាល័យស្រុកប្រតិបត្តិចំនួន ០៧
- មន្ទីរពេទ្យបង្អែកថ្នាក់រាជធានី ( កម្រិត CPA3) ចំនួន ០១
- មន្ទីរពេទ្យបង្អែកថ្នាក់ស្រុក ( កម្រិត CPA1) ចំនួន ០៧
- មណ្ឌលសុខភាព ( កម្រិត MPA) ចំនួន ៣៩
- និងប៉ុស្តិ៍សុខភាព ចំនួន ១២

**ជាលទ្ធផលៈ**

១- មណ្ឌលផ្តល់ប្រឹក្សា ធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់មាន ៤កន្លែង:

- មន្ទីរពេទ្យបង្អែកដង្កោ
- មន្ទីរពេទ្យបង្អែកពោធិ៍ចិនតុង
- មន្ទីរពេទ្យបង្អែកសម្តេចឪ
- មន្ទីរពេទ្យបង្អែកមានជ័យ

ធ្វើតេស្តបានចំនួន ៥៨៣០នាក់ ក្នុងនោះលទ្ធផលវិជ្ជមាន ១៩៩នាក់

- ការធ្វើតេស្តឈាមនៅមណ្ឌលសុខភាពទាំង៣៩កន្លែង : បានចំនួន ៣៥២៤៨នាក់ លទ្ធផលមាន ៨០នាក់ ជាតេស្តប្រតិកម្ម។

២- មណ្ឌលផ្តល់ថ្នាំឱកាសនិយម និងថ្នាំប្រឆាំងមេរោគអេដស៍ទាំង ៤កន្លែង :

មានអ្នកជំងឺអេដស៍ចំនួន ២០៧៤ នាក់ ក្នុងនោះបានទទួលថ្នាំឱកាសនិយម ៧០នាក់ និងថ្នាំប្រឆាំងមេរោគអេដស៍ ចំនួន ២០០៤ នាក់ ។

- ការគ្រប់គ្រងករណីអេដស៍សកម្ម មានចំនួន ៦០២នាក់ បញ្ជូនទៅទទួលសេវា ចំនួន ៥៦៨នាក់ បាត់ ៣៤នាក់ ។

៣- អ្នកចូលរួមក្នុងការគ្រប់គ្រងករណីអេដស៍សកម្មរួមមាន :

អ្នកសម្រមបសម្រួលកម្មវិធីអេដស៍មន្ទីរសុខាភិបាល ស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក មន្ទីរពេទ្យថ្នាក់ជាតិ ដូចជាមន្ទីរពេទ្យកាល់ម៉ែត្រ មន្ទីរពេទ្យព្រះកុសមៈ មន្ទីរពេទ្យព្រះកេតុមាលា មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត គ្លីនិកសង្គម មជ្ឈមណ្ឌលគាំពារមាតានិងទារក មជ្ឈមណ្ឌលកំចាត់រោគរបេង និងហង់សិន មន្ទីរពេទ្យ Hope Center មន្ទីរពេទ្យកុមារជាតិ។

ចំពោះអង្គការមាន: - ឈូកស១ - ឈូកស២ - RHAC និង NGO ផ្សេងៗទៀត បានធ្វើការអប់រំ និងធ្វើតេស្តឈាមរកមេរោគអេដស៍ តាមសេវាកំសាន្តសប្បាយ និងយុទ្ធនាការផ្សេងៗទៀត។

ការអនុវត្តន៍ទៅតាមយុទ្ធសាស្ត្រកម្ពុជា ៣.០ ដើម្បីឈានឆ្ពោះទៅរកការលប់បំបាត់ការឆ្លងថ្មី នៅឆ្នាំ ២០២០ តាមរយៈ៖

- យុទ្ធវិធីជំរុញគ្រប់គ្រងខ្លាំងក្លាការបង្ការ ថែទាំ និងព្យាបាលបន្ត ដល់ក្រុមប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ ( Boosted Continuum of Prevention to care and Treatment for Most at Risk Population ) ។

- យុទ្ធវិធីជំរុញខ្លាំងក្លាការថែទាំ និង ព្យាបាលបន្តដល់អ្នកផ្ទុក និងអ្នកជំងឺអេដស៍។

- យុទ្ធវិធីជំរុញខ្លាំងក្លា ការអនុវត្តវិធីសាស្ត្រឆ្លើយតបរួមគ្នារវាងសេវាបង្ការ ថែទាំ និងព្យាបាលជំងឺអេដស៍ សុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ដើម្បីឈានទៅលប់បំបាត់ការឆ្លងមេរោគអេដស៍ពីម្តាយទៅកូន និងលប់បំបាត់ការឆ្លងមេរោគស្វាយពីកំណើត ( Boosted LR ) ។

- ការគ្រប់គ្រងសកម្មករណីនៃជំងឺអេដស៍ ( Integrated Active Case Management ) ។

**<u>តំណាងអង្គការ FHI 360</u>៖** គម្រោង Flagship បានធ្វើសកម្មភាពទៅលើក្រុមស្ត្រីបំរើសេវាកំសាន្តសប្បាយនៅក្នុងស្រុកប្រតិបត្តិចតុមុខ។ បញ្ហាប្រឈមគឺហាងមួយចំនួនពិបាកក្នុងការចូលទៅអប់រំ ដោយសារស្ត្រីពិបាកក្នុងការជួប។

**<u>ប្រធានបទទី៣</u>៖ លោកវេជ្ជបណ្ឌិត ឆេព ណារ៉ាឌុច** ប្រធាននាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានធ្វើបទបង្ហាញរបាយការណ៍ការអង្កេតថ្នាក់ជាតិលើកទី៥ ស្តីពីការចំណាយលើការឆ្លើយតបនឹងមេរោគអេដស៍/ជំងឺអេដស៍ សម្រាប់ឆ្នាំ២០១៤ និង២០១៥ ក្នុងគោលបំណង៖

-ផ្តល់ព័ត៌មានលម្អិតលើលំហូរថវិកា បរិមាណចំណាយ និងអ្នកដែលទទួលផល

-ផ្តល់ភស្តុតាងលម្អិតពីការចំណាយលើការងារអេដស៍ក្នុងឆ្នាំ២០១៤ និង២០១៥

-អនុញ្ញាតឱ្យអ្នកពាក់ព័ន្ធគណនាកង្វះខាតថវិកាសម្រាប់បទអន្តរាគមន៍ជាក់លាក់លើការងារបង្ការ ព្យាបាល ថែទាំ និងគាំទ្រ។

-ជួយឱ្យអ្នកពាក់ព័ន្ធបានយល់ថាតើការឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍ ត្រូវផ្តល់ថវិកាយ៉ាងដូចម្តេច?

-បង្ហាញភស្តុតាងថាអន្តរាគមន៍ណាមួយកំពុងមានថវិកា និងគុណតម្លៃនៃបទអន្តរាគមន៍

-ជួយឱ្យប្រទេសកម្ពុជាចាត់ជាអាទិភាពបទអន្តរាគមន៍ដែលមានប្រសិទ្ធិភាពខ្ពស់ចំណាយទាប និងទទួលបានលទ្ធផលអតិបរិមា។

ការសង្កេតជាទូទៅការចំណាយលើការងារអេដស៍គឺ៥០៨៨៣៧១៨ដុល្លារអាមេរិក នៅឆ្នាំ២០១២ និង ៤៩១២១៨០៥ដុល្លារអាមេរិក នៅឆ្នាំ២០១៤ ព្រមទាំងចំនួន៤៦៨៦៤៤០៩ដុល្លារអាមេរិក នៅឆ្នាំ២០១៥។

<u>ការសង្កេតជាគន្លឹះ</u>៖

- ៨៣% នៃការចំណាយនៅឆ្នាំ២០១៥ ជាជំនួយថវិកាពីខាងក្រៅ
- ជំនួយទី១ធំជាងគេ គឺមូលនិធិសកល និងបានថយចុះពីឆ្នាំ២០១៤-២០១៥ ប្រមាណ២២%
- ជំនួយធំទី២ គឺ PEPFAR ប្រមាណ៣០% ក្នុងឆ្នាំ២០១៥
- ថវិកាជាតិមានការកើនឡើងចាប់ពីឆ្នាំ២០១០មក ដូចជា៦៤៣៨២៣០ដុល្លារអាមេរិក នៅឆ្នាំ២០១៤ និង៨១៨៨១៦១ដុល្លារអាមេរិកនៅឆ្នាំ២០១៥។

- ❖ ការព្យាបាល និងការថែទាំចំណាយប្រមាណ ១៩លានដុល្លារ និងការបង្ការប្រមាណ ១១លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ។ ការគ្រប់គ្រងគម្រោងចន្លោះពី៦-៨លានដុល្លារអាមេរិក ។

**ការសង្កេត និងការអនុវត្តន៍តាមគោលនយោបាយ៖**

-ការអនុវត្តន៍តាមគោលនយោបាយ៖

- ❖ ការចំណាយថវិកាជាតិមានការកើនឡើងសម្រាប់ការងារអេដស៍ ដែលជាកត្តាសំខាន់នៅពេលដែលជំនួយពីខាងក្រៅថយចុះ។
- ❖ មានការកើនឡើងការចំណាយមានប្រសិទ្ធិភាព cost-effectiveness និងវិភាគពីផលប្រយោជន៍ cost-benefit analysis ដើម្បីកំណត់កន្លែងដែលខ្វះខាតធនធាន ដើម្បីវិភាជថវិកា។

មានការខិតជិត លើការវិភាជថវិការបស់រដ្ឋាភិបាលស្តីពីការចំណាយដើម្បីជានាដល់ការសម្របសម្រួល និងការសហការគ្នា។

**អនុសាសន៍សម្រាប់ការធ្វើ NASA លើកក្រោយ៖**

-បង្កើតកូដស្វ័យប្រវត្តិសម្រាប់អ្នកពាក់ព័ន្ធ៖

- ❖ ការចំណាយពេលច្រើនលើការដាក់កូដ ដូច្នេះត្រូវមានកូដស្វ័យប្រវត្តិក្នុងទម្រង់ប្រមូលទិន្នន័យ
- ❖ បង្កើនការសម្របសម្រួលជាមួយការតាមដានការចំណាយធនធានផ្សេងទៀតដើម្បីកាត់បន្ថយពេលវេលា និងបានទិន្នន័យដូចគ្នា Consistency ជាពិសេសជាមួយទិន្នន័យសុខាភិបាល។
- ❖ គណនេយ្យជាតិ សុខាភិបាល National Health Account និង NASA ត្រូវធ្វើក្នុងពេលតែមួយគួរតែបង្កើតការសម្របសម្រួលរវាង NASA និង NHA។

**ការប្រឈម CHALLENGES៖**

-ខ្វះខាតទិន្នន័យដែលអាចបែងចែកដាច់៖

- ❖ កម្មវិធីអេដស៍ និងការផ្តល់សេវាកាន់តែមានការបញ្ជ្រាបចូលគ្នា more integrated
- ❖ ការចាត់ថ្នាក់ចំណាយ NASAទាមទារការចាត់ថ្នាក់តាមកម្រិត
- ❖ មានជំពូកចំណាយជាច្រើន មិនអាចបែងចែកដាច់ឡើយ

-ការប្រៀបធៀបការចំណាយតាមផែនការយុទ្ធសាស្ត្រជាតិនៅមានកម្រិតនៅឡើយ៖

- ❖ កូដទាំងអស់ ដូចជាកូដរបស់NASA លើកទី៤ ឧទាហរណ៍កូដ ASC04 (ការគ្រប់គ្រងគម្រោង និងរដ្ឋបាល) ត្រូវបានបញ្ជ្រាបក្នុងការឆ្លើយតបអេដស៍ជារួម និងមិនមែនសម្រាប់តែការងាររដ្ឋបាលគម្រោងប៉ុណ្ណោះទេ។

**ប្រធានបទទី៤៖ ឯកឧត្តម ឈឹម ឃិនដារ៉េត** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានធ្វើបទបង្ហាញពីការរៀបចំផែនការកម្មវិធីនៃការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ របស់ក្រសួង-ស្ថាប័នឆ្នាំ២០១៨៖

ឯកឧត្តម បានផ្តល់អនុសាសន៍ថា ជាការល្អ ក្រសួងជាសមាជិកគួររៀបចំផែនការថវិកាដោយជ្រៀតចូលក្នុងសកម្មភាព ជាងការជ្រៀតចូលក្នុងអនុកម្មវិធីឬកម្មវិធី។

សមាជិកអង្គប្រជុំស្នើសុំឱ្យអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បញ្ជូនឯកសារបទដ្ឋានគតិយុត្តតាមក្រសួងដូចជាៈ

១/អនុក្រឹត្យលេខ២១៦អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុងប្រទេស និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មាន៦ជំពូក និង២៧មាត្រា។

២/ប្រកាសលេខ១៥៨៩សហវ.ប្រក ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីវិធាន និងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងប្រទេស និង ក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ មាន ៦ ជំពូក និង២៧ ប្រការ។

បន្ទាប់មកឯកឧត្តមប្រធានអង្គប្រជុំ ក៏បានជម្រាបជូនដល់សមាជិក-សមាជិកានៃអង្គប្រជុំថា **កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី៤ នឹងប្រព្រឹត្តទៅនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧** ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង១១ និង១៥នាទី ថ្ងៃ ខែ ឆ្នាំ ដដែល ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត។

**<u>ឧបសម្ព័ន្ធ៖</u>**

- បញ្ជីវត្តមានអ្នកចូលរួម
- ឯកសារបទបង្ហាញផ្សេងៗ

ភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧

**ប្រធាននាយកដ្ឋាន**

**ទាក់ទង និងចលនាប្រភពធនធាន**

**វេជ្ជ. ឈា សិទ្ធិ**

បានឃើញ និងឯកភាព

**អគ្គលេខាធិការ**